SAPC | Substance Abuse Prevention and Control

# ការរក្សាការសម្ងាត់ និងការអនុញ្ញាត

ខោនធីនេះ (សំដៅទៅលើកម្មវិធីទប់ស្កាត់ និងគ្រប់គ្រងការប្រើប្រាស់សារធាតុញៀន [Substance Abuse Prevention and Control/SAPC]) បណ្ដាញអ្នកផ្តល់សេវាកម្មផ្នែកការព្យាបាលរបស់ពួកគេ និងអ្នកជំនាញផ្នែកការថែទាំសុខភាពផ្សេងទៀត គោរពតាមបទបញ្ញានានាដែលការពារការរក្សាការសម្ងាត់នៃកំណត់ត្រាទាំងឡាយរបស់អ្នក ហើយនិងអត្តសញ្ញាណរបស់អ្នកផងដែរ ចំពោះចំណុចណាដែលទាក់ទង។ អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលជាប់កិច្ចសន្យាជាមួយនឹងខោនធីនេះ (SAPC) ទាំងអស់គឺតម្រូវចាំបាច់ត្រូវបង្កើតគោលការណ៍ និងនីតិវិធីផ្សេងៗដែលទាក់ទងទៅនឹងការរក្សាការសម្ងាត់ ហើយនិងគោរពតាមចំណងជើង 42 ជំពូក I ជំពូករង A ផ្នែក 2 របស់ច្បាប់នៃបទបញ្ញារបស់រដ្ឋាភិបាល (Title 42, Chapter I, Subchapter A, Part 2 of the Code of Federal Regulations, Part 2/42 CFR Part 2) ព្រមទាំងបទដ្ឋាននានារបស់ច្បាប់នៃការអាចបន្តប្រើប្រាស់ និងការទទួលខុសត្រូវរបស់ធានារ៉ាប់រងសុខភាព (Health Insurance Portability and Accountability Act/HIPAA) ហើយនិងច្បាប់របស់រដ្ឋ California ទាក់ទងទៅនឹងការរក្សាការសម្ងាត់ចំពោះព័ត៌មានអំពីកំណត់ត្រាផ្សេងៗផ្នែកពេទ្យរបស់អ្នក ដោយរួមមានកំណត់ត្រាទាំងឡាយដែលពាក់ព័ន្ធទៅនឹងការពិសាជាតិអាល់កុល (សុរា) និងការប្រើប្រាស់គ្រឿងញៀន ផងដែរ។

អ្នកមានសិទ្ធិក្នុងការរក្សាទុកកំណត់ត្រាផ្នែកពេទ្យរបស់អ្នកជាការសម្ងាត់។ ប្រសិនបើអ្នកកំពុងស្វែងរក ឬកំពុងទទួលបានសេវាកម្មផ្សេងៗសម្រាប់បញ្ហាដែលទាក់ទងទៅនឹងគ្រឿងញៀន ឬជាតិអាល់កុលនោះ អ្នកមានការគាំពារបន្ថែមទៀត ដើម្បីធានាថាអ្នកអាចស្វែងរកការព្យាបាល និងសេវាកម្មផ្នែកការជាសះស្បើយឡើងវិញបានដោយសុវត្ថិភាព និងដោយមានការលាក់កំបាំង ហើយដោយមិនមានការភ័យខ្លាចចំពោះគំនិតអវិជ្ជមាន ឬការចោទប្រកាន់ឡើយ។ គ្រូពេទ្យរបស់អ្នក ឬអ្នកផ្តល់សេវាកម្មផ្នែកការព្យាបាល ឬក៏ខោនធីនេះ (SAPC) មិនអាចបង្ហាញចេញថាអ្នកបានស្វែងរក ឬកំពុងទទួលការព្យាបាលពាក់ព័ន្ធទៅនឹងការប្រើប្រាស់សារធាតុញៀន ទៅកាន់បុគ្គលទាំងឡាយដែលមិនបានទទួលការអនុញ្ញាតឡើយ រួមមានក្រុមគ្រួសារ ម្ចាស់អាជីវកម្មឬកន្លែងការរបស់អ្នក ឬក៏សូម្បីតែមន្ត្រីប៉ូលីសដែលមិនមានដីកា (បទបញ្ញា)

របស់តុលាការត្រឹមត្រូវមួយ ផងដែរ។ ព័ត៌មានណាមួយដែលអាចកំណត់អត្តសញ្ញាណរបស់អ្នកដោយផ្ទាល់
ឬដោយប្រយោល ថាកំពុងមានបញ្ហាទាក់ទងទៅនឹងគ្រឿងញៀន ឬជាតិអាល់កុលនាពេលឥឡូវនេះ
ឬពីពេលកន្លងមក ឬក៏ថាជាអ្នកចូលរួមក្នុងកម្មវិធីព្យាបាលមួយនោះ គឺមានការគាំពារ។

ទោះជាយ៉ាងណាក៏ដោយ ការធ្វើឱ្យច្បាប់
និងបទបញ្ញាទាំងនេះមានភាពស្មើគ្នាធៀបនឹងតម្រូវការក្នុងការផ្តល់ការថែទាំប្រកបដោយការយល់ដឹង
មានភាពសម្របសម្រួលត្រឹមត្រូវ និងរួមបញ្ចូលគ្នាជូនដល់អ្នកនោះ គឺជាការសំខាន់។

អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកអាចនឹងស្នើសុំឱ្យអ្នកចុះហត្ថលេខានៅបែបបទបញ្ចេញព័ត៌
មានរបស់អ្នកជំងឺ និង/ឬបែបបទការអនុញ្ញាតរបស់អ្នកជំងឺ
ដែលអាចនឹងរួមមានសិទ្ធិក្នុងការចែករំលែកព័ត៌មានផ្នែកការព្យាបាលជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែក
ថែទាំទាំងឡាយដែលមានការពាក់ព័ន្ធ នៅតាមប្រព័ន្ធនៃការថែទាំនានា ផងដែរ។
ចំណុចនេះរួមមានបណ្តាញអ្នកផ្តល់សេវាកម្មផ្នែកការព្យាបាលផ្សេងទៀត
ឬផែនការថែទាំសុខភាពរបស់អ្នក (ឧ. Anthem Blue Cross, Health Net, Kaiser Permanente, L.A.
Care, Molina Health Care) ឬក៏គ្រូពេទ្យដែលទទួលបន្ទុកព្យាបាល (ម្នាក់

ឬច្រើននាក់) ហើយនិងទីភ្នាក់ងារថ្នាក់ខោនធីផ្សេងទៀត ទៅតាមការចាំបាច់។
មូលហេតុនៃការធ្វើដូចនេះគឺដើម្បីជួយឱ្យមនុស្សគ្រប់រូបផ្តល់ការថែទាំដែលកាន់តែល្អជូនដល់អ្នក
ហើយនិងជួយឱ្យអ្នកស្របតាមគោលបំណងផ្សេងៗផ្នែកសុខភាព
និងផ្នែកការជាសះស្បើយឡើងវិញរបស់អ្នក ផងដែរ។

មុនពេលដែលអ្នកផ្តល់សេវាកម្មផ្នែកការព្យាបាលរបស់អ្នកប្រគល់ព័ត៌មានផ្នែកសុខភាពរបស់អ្នកជូនទៅ
នរណាម្នាក់ផ្សេងទៀតនោះ អ្នកត្រូវតែផ្តល់ការយល់ព្រមរបស់អ្នកជាលាយលក្ខណ៍អក្សរ ជាទូទៅគឺតាម
រយៈការចុះហត្ថលេខានៅលើបែបបទមួយ។
មានកាលៈទេសៈផ្សេងៗដែលអ្នកផ្តល់សេវាកម្មផ្នែកការព្យាបាលរបស់អ្នកអាចនឹងចែករំលែកព័ត៌មានដែ
លអាចកំណត់អត្តសញ្ញាណអ្នកថាជាអ្នកជំងឺបាននោះ រួមមានក្នុងគ្រាដែលមានករណីបន្ទាន់ផ្នែកពេទ្យ
ឬក៏ចំពោះការរាយការណ៍អំពីបទល្មើសដែលកើតឡើងនៅក្នុងបរិវេណកម្មវិធី
ឬបទល្មើសដែលកើតឡើងប្រឆាំងទៅនឹងបុគ្គលិក

ឬក៏ដើម្បីចែករំលែកទៅកាន់អង្គភាពផ្តល់សេវាកម្មនានាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (qualified service organizations)។

ការដែលអ្នកយល់ដឹងអំពីការកំណត់ និងវិសាលភាព (កម្រិត) នៃសិទ្ធិចំពោះការរក្សាការសម្ងាត់របស់អ្នកនោះ គឺជាការសំខាន់។ ធ្វើឱ្យប្រាកដថាអ្នកសាកសួរសំណួរផ្សេងៗទៅតាមតម្រូវការ ដើម្បីធានាថាអ្នកផ្តល់នូវការអនុញ្ញាតដោយមានការយល់ដឹង មុនពេលការចុះហត្ថលេខានៅលើបែបបទផ្តល់ការអនុញ្ញាតណាមួយនោះ។